WISe
Wraparound with Intensive Services

# WISe: Families

## តើ **WISe** គឺជាអ្វី?

WISe គឺជាសេវាស្ម័គ្រចិត្តមួយដែលប្រើប្រាស់វិធីសាស្ត្រជាក្រុមមួយ ដើម្បីបំពេញតាមតម្រូវការរបស់កូនអ្នក។ វាផ្តល់សេវាសុខភាពខួរក្បាល យ៉ាងល្អិតល្អន់ដើម្បីគាំទ្រកូនរបស់អ្នក និងជួយដល់គ្រួសាររបស់អ្នក នៅក្នុងការឈានទៅសម្រេចគោលដៅរបស់ខ្លួន។

## ការផ្តោតរបស់ **WISe** គឺ៖

- ផ្តល់សេវាសុខភាពខួរក្បាលយ៉ាងល្អិតល្អន់ដែលត្រូវបានបង្កើតឡើង ដើម្បីជួយដល់កូនរបស់អ្នក និងគ្រួសាររបស់អ្នកឲ្យសម្រេចបាននូវ សុខមាលភាព សុវត្ថិភាព និងដើម្បីពង្រឹងទំនាក់ទំនងជាមួយ សហគមន៍របស់អ្នក។
- អភិវឌ្ឍផែនការថែទាំជាលក្ខណៈផ្ទាល់ខ្លួនមួយ ដោយផ្អែកតាម ចំណុចខ្លាំង និងតម្រូវការដែលគោរពវប្បធម៌ គុណតម្លៃ បទដ្ឋាន និងចំណូលចិត្តរបស់គ្រួសារអ្នក។ កូន និងគ្រួសាររបស់អ្នកផ្តល់ការណែនាំ និងដឹកនាំផែនការនេះ ដោយប្រើប្រាស់ក្រុមការងារមួយ។ សមាជិកក្រុមការងារ រួមមាន ការគាំទ្រពីធម្មជាតិ (ដូចជា គ្រួសារ មិត្តភ័ក្តិ និងអ្នកដឹកនាំផ្នែកសាសនា) និងអ្នកជំនាញដែលធ្វើការ ជាមួយគ្រួសាររបស់អ្នក (ដូចជា ទីប្រឹក្សា សាលារៀន CPS និងមន្ត្រីសង្គមកិច្ចដែលធ្វើការជាមួយអ្នកដែលមានបញ្ហាសុខភាព (probation officers)។
- ស្នើផ្តល់នូវសេវា និងការគាំទ្រនានានៅតាមទីតាំងនានា និងនៅ ពេលដែលការងារនោះមានភាពល្អបំផុតចំពោះកូន និង គ្រួសាររបស់ អ្នក (ដែលរួមបញ្ចូលទាំងនៅក្នុងផ្ទះរបស់អ្នក ឬនៅទីសាធារណៈ ណាមួយតាមជម្រើសរបស់អ្នក និងនៅពេលល្ងាច ឬនៅចុងសប្តាហ៍)។
- សម្គាល់ឃើញ ឬផ្តល់ជូនធនធាន និងការគាំទ្រនានាដល់កូន និង គ្រួសាររបស់អ្នក។
- ផ្តល់ជំនួយនៅក្នុងអំឡុងពេលមានវិបត្តិ។ អ្នកអាចប្រើប្រាស់សេវា នៅពេលមានវិបត្តិសម្រាប់កូនរបស់អ្នកនៅគ្រប់ពេលវេលាទាំងអស់ នៅក្នុងរយៈពេល 365 ក្នុងមួយឆ្នាំ។ កូនរបស់អ្នកនឹងទទួលបានសេវា នានាពីបុគ្គលទាំងឡាយដែលដឹងអំពីតម្រូវការ និងកាលៈទេសៈរបស់ កូន និងគ្រួសាររបស់អ្នក ព្រមទាំងផែនការសម្រាប់អ្នកមានវិបត្តិនា ពេលបច្ចុប្បន្នរបស់ពួកគេផងដែរ។ នៅពេលណាមួយដែលមានការ ចាំបាច់ នេះរួមបញ្ចូលទាំងការធ្វើអន្តរាគមន៍ដោយផ្ទាល់នៅទីកន្លែង ដែលវិបត្តិនោះកើតឡើងផងដែរ។

## តើអ្នកណាខ្លះអាចទទួលបាន **WISe**?

WISe អាចស្វែងរកបានសម្រាប់យុវជនដែលមានសិទ្ធិទទួលបាន Medicaid រហូតដល់ពួកគេមានអាយុ 21 ឆ្នាំ ដែលបំពេញតាមស្តង់ដារ ក្នុងការទទួលបានការថែទាំ (ស្តង់ដារដែលត្រូវបានប្រើប្រាស់ដោយ ទីភ្នាក់ងារផ្នែកសុខភាពខួរក្បាលដើម្បីទទួលបានកម្រិតដែលត្រឹមត្រូវនៅ ក្នុងការផ្តល់សេវានានាជូនបុគ្គលទាំងឡាយ)។

### គោលការណ៍គ្រឹះ **WISe** ៖

តម្លៃ **WISe** ដែលជួយពង្រឹងលទ្ធផលសម្រាប់កុមារ ៖

1. សំឡេង និងជម្រើសរបស់គ្រួសារ និងយុវជន
2. ផ្អែកលើក្រុមការងារ
3. ការគាំទ្រខាងធម្មជាតិ
4. កិច្ចសហការ
5. ផ្អែកតាមផ្ទះ និងសហគមន៍
6. ពាក់ព័ន្ធខាងវប្បធម៌
7. ដែលធ្វើជាបុគ្គល
8. ផ្អែកលើកម្លាំង
9. ផ្អែកលើលទ្ធផល
10. ឥតលក្ខខណ្ឌ

## តើនៅពេលណាខ្លះដែលអាចមានសារប្រយោជន៍ចំពោះខ្ញុំនៅក្នុងការប្រើប្រាស់ **WISe?**

អ្នកអាចបញ្ជូនកូនរបស់អ្នកទៅធ្វើការត្រួតពិនិត្យ WISe នៅគ្រប់ពេល វេលាទាំងអស់។ មាតាបិតាអាចផ្តួចផ្តើមគំនិតចំពោះការព្យាបាលបាន ប៉ុន្តែនៅក្រោយអាយុ 13 ឆ្នាំ កុមារត្រូវតែយល់ព្រមចំពោះសេវានានា។ អ្នកគួរពិចារណាអំពីការបញ្ជូនកូនរបស់អ្នកទៅធ្វើការត្រួតពិនិត្យ WISe ប្រសិនបើគាត់/នាងគឺជា៖

- អ្នកប្រើប្រាស់ខ្សែទូរស័ព្ទសម្រាប់អ្នកមានវិបត្តិ ឬបន្ទប់សម្រាប់ គ្រាអាសន្នជាញឹកញាប់ ដោយសារកង្វល់នានាអំពីសុខភាពខួរក្បាល របស់កូនអ្នក។
- មានការលំបាកនៅក្នុងការស្វែងយល់អំពីឥរិយាបថនានា (ដូចជា ការរត់គេចខ្លួន ឬការចាប់ខ្លួនជាញឹកញាប់ដោយសារសុខភាព ខួរក្បាល) ដែលអ្នក អ្នកថែទាំដទៃទៀត ឬអ្នកព្យាបាល/គ្រូពេទ្យពិនិត្យ អ្នកជំងឺដោយផ្ទាល់កំពុងតែប្រឈមមុខនឹងបញ្ហានេះ ហើយសេវាតាម បែបបុរាណតែមួយមុខមិនអាចជួយដោះស្រាយបញ្ហានេះបាននោះទេ។
- បង្ហាញអំពីហានិភ័យនៃសេចក្តីអន្តរាយនានាដែលមានការកើនឡើង ចំពោះខ្លួនពួកគេ និងអ្នកដទៃ។
- ត្រូវការ វិធីសាស្ត្រក្នុងការព្យាបាលដែលកាន់តែមានភាពល្អិតល្អន់ និងមានភាពផ្ទាល់ខ្លួន។
- ត្រូវការវិធីសាស្ត្រដែលមានភាពបត់បែន និងមានការចូលរួមច្រើនជាង មុន។
- ចូលរួមនៅក្នុងពហុប្រព័ន្ធ (ពោលគឺ សុខភាពខួរក្បាល, សុខមាលភាពកុមារ (CPS), យុត្តិធម៌របស់អនីតិជន, សេវាពិការភាព ផ្នែកការអភិវឌ្ឍ និង/ឬការព្យាបាលវិបល្លាសនៃការប្រើប្រាស់សារធាតុ នានា) និងប្រព័ន្ធ(នានា) ដែលកំពុងតែខិតខំប្រឹងប្រែងដើម្បីផ្តល់ការ គាំទ្រដល់កូនរបស់អ្នកជាមួយគ្នា។
- នៅក្នុងការអប់រំពិសេស និង/ឬមានផែនការ 504 មួយជាមួយការ ព្យួរការសិក្សានៅសាលារៀនជាច្រើនដោយសារសុខភាពខួរក្បាល និង/ឬបញ្ហាផ្នែកឥរិយាបថ។



Washington State
Health Care Authority

## តើខ្ញុំបញ្ជូនកូនរបស់ខ្ញុំទៅទទួលយក **WISe** ដោយរបៀបណា?

ការបញ្ជូនទៅកាន់ការត្រួតពិនិត្យ WISe អាចធ្វើឡើងនៅគ្រប់ពេលវេលាទាំងអស់។ ដើម្បីស្វែងរកបុគ្គលដែលអ្នកត្រូវទាក់ទងទៅកាន់ សូមចូលទៅ៖https://www.hca.wa.gov/assets/free-or-low-cost/wise-referral-contact-list-by-county.pdf និងចុចលើឯកសារ "បញ្ជីឈ្មោះបុគ្គលទំនាក់ទំនងសម្រាប់ការបញ្ជូនទៅទទួលយក WISe តាមខោនធី"។

ប្រសិនបើជឿជាក់ថាកូនរបស់អ្នកនឹងទទួលបានអត្ថប្រយោជន៍ពីសេវាសុខភាពខួរក្បាលនោះ សូមប្រើប្រាស់ព័ត៌មានទំនាក់ទំនងដែលមាននៅលើគេហទំព័រនេះ នៅខាងលើ ដើម្បីធ្វើការបញ្ជូនណាមួយ ឬហៅទូរស័ព្ទដោយឥតគិតថ្លៃទៅកាន់ខ្សែទូរស័ព្ទផ្តល់ជំនួយសម្រាប់ការជាពីជំងឺតាមរយៈលេខ 866-789-1511។

## តើខ្ញុំអាចរំពឹងទុកថានឹងទទួលបានអ្វីខ្លះ?

រាល់ការបញ្ជូនទាំងអស់គួរតែបណ្តាលឲ្យមានការត្រួតពិនិត្យ CANS (វិធីសាស្រ្តសម្រាប់តម្រូវការ និងចំណុចខ្លាំងរបស់កុមារ និងមនុស្សវ័យជំទង់)។ ការត្រួតពិនិត្យ CANS ត្រូវតែបានផ្តល់ជូននៅក្នុងរយៈពេល 10 ថ្ងៃធ្វើការបន្ទាប់ពីទទួលបានការបញ្ជូនណាមួយ។ រាល់ការត្រួតពិនិត្យ CANS ទាំងអស់រួមបញ្ចូល៖

ការប្រមូលផ្តុំព័ត៌មានដើម្បីបំពេញការត្រួតពិនិត្យ CANS ដែលរួមមានសំណួរចំនួន 26 ផ្នែកតូចៗ។ ការត្រួតពិនិត្យនេះនឹងកំណត់ថាតើកូនរបស់អ្នកនឹងអាចទទួលបានអត្ថប្រយោជន៍ពីកម្រិតនៃការថែទាំដែល WISe ផ្តល់ជូនដែរឬទេ។ វិធីសាស្រ្តក្នុងការត្រួតពិនិត្យនេះអាចត្រូវបានបំពេញតាមរយៈទូរស័ព្ទ ឬជាមួយបុគ្គលនោះដោយផ្ទាល់។

នៅពេលដែលវិធីសាស្រ្តក្នុងការត្រួតពិនិត្យនេះបង្ហាញថា WISe អាចផ្តល់អត្ថប្រយោជន៍ជាសក្តានុពលដល់កូនរបស់អ្នកបាននោះ កូនរបស់អ្នកនឹងត្រូវបានបញ្ជូនទៅកាន់ទីភ្នាក់ងាររបស់ WISe ធ្វើដូច្នេះការវាយតម្លៃអំពីការចូលរួមមួយអាចត្រូវបានបញ្ចប់រួចរាល់។ បន្ទាប់មកទៀត ទីភ្នាក់ងារអ្នកផ្តល់ WISe នឹងចាត់តាំងក្រុមការងារថ្មីមួយសម្រាប់កូនរបស់អ្នក ហើយរាល់ការថែទាំទាំងអស់នឹងត្រូវបានសម្របសម្រួលតាមរយៈទីភ្នាក់ងារ/ក្រុមការងារនោះ។

ប្រសិនបើត្រូវបានកំណត់កូនរបស់អ្នកមិនបានបំពេញតាមកម្រិតនៃការថែទាំដែល WISe ផ្តល់ជូនទេនោះ កូនរបស់អ្នកនឹងត្រូវបានបញ្ជូនទៅកាន់សេវាសុខភាពខួរក្បាលផ្សេងទៀត តាមភាពសមស្រប ដើម្បីដោះស្រាយតម្រូវការរបស់គាត់/នាង។

## តើអ្នកមានបំណងចង់ចូលរួមដែរឬទេ?

មតិយោបល់របស់អ្នកអាចជួយធ្វើឲ្យសេវាសម្រាប់កុមារ និងយុវជនមានភាពល្អប្រសើរឡើង។ កិច្ចប្រជុំតុមូលរបស់គ្រួសារ យុវជន និងដៃគូនៃប្រព័ន្ធ (FYSPRTs)  គឺជាផ្នែកដ៏សំខាន់មួយនៃរចនាសម្ព័ន្ធអភិបាលកិច្ចដែលកំពុងតែដំណើរការដើម្បីធ្វើឲ្យប្រព័ន្ធសុខភាពផ្នែកឥរិយាបថរបស់កុមារ ដែលរួមបញ្ចូលទាំង WISe ផងដែរ មានភាពល្អប្រសើរឡើង។ ស្វែងយល់បន្ថែមនៅទីនេះ៖ https://www.hca.wa.gov/fysprt

### ដំណើរការគ្រប់ជ្រុងជ្រោយរបស់រដ្ឋវ៉ាស៊ីងតោនចំពោះសេវាសុខភាពធ្ងន់ធ្ងរ **(WISe)**

*ទិដ្ឋភាពទូទៅនៃ T.R. et al. v. Strange and Birch*

*នៅខែវិច្ឆិកា ឆ្នាំ 2009 រឿងក្តី Medicaid មួយត្រូវបានដាក់ (កាលពីមុន ហៅថា T.R. v. Dreyfus) ប្រឆាំងនឹងក្រសួងសេវាសង្គម និងសុខាភិបាល និងអាជ្ញាធរថែទាំសុខភាព អំពីសេវាសុខភាពខួរក្បាលធ្ងន់ធ្ងរសម្រាប់កុមារ និងយុវជន។ រឿងក្តីនោះ គឺផ្តែកលើច្បាប់ស្តី EPSDT (ការត្រួតពិនិត្យ ការធ្វើរោគវិនិច្ឆ័យ និងការព្យាបាលនៅដំណាក់កាលដំបូង និងជាទៀងទាត់) របស់សហព័ន្ធ ដែលតម្រូវឲ្យរដ្ឋផ្តល់ជូនទូវសេវាសុខភាពខួរក្បាល និងការព្យាបាលដល់កុមារដែលត្រូវការសេវា និងការព្យាបាលទាំងនោះ ទោះបីជាសេវាទាំងនេះមិនត្រូវបានផ្តល់ជូនកាលពីមុនមកក៏ដោយ។ ក្រោយពេលចរចាគ្នាអស់រយៈពេលជាច្រើនឆ្នាំមក ភាគីទាំងពីរបានព្រមព្រៀងគ្នាលើផែនការមួយដែលពួកគេជឿជាក់ថានឹងធ្វើឲ្យពួកគេអនុលោមតាមច្បាប់ និងអ្វីដែលសំខាន់បំផុតនោះគឺការធ្វើការដើម្បីយុវជន និងគ្រួសារទាំងឡាយនៅក្នុងរដ្ឋវ៉ាស៊ីងតោន។ តុលាការសហព័ន្ធបានឯកភាពចំពោះកិច្ចព្រមព្រៀងស្តីពីដំណោះស្រាយនេះនៅថ្ងៃទី 19 ខែធ្នូ ឆ្នាំ 2013។ គោលដៅរបស់កិច្ចព្រមព្រៀងស្តីពីដំណោះស្រាយនេះ គឺដើម្បីអភិវឌ្ឍប្រព័ន្ធមួយដែលផ្តល់សេវាសុខភាពខួរក្បាលធ្ងន់ធ្ងរនៅផ្ទះ និងនៅទីកន្លែងនានានៅក្នុងសហគមន៍ ដែលដំណើរការសម្រាប់ - សម្រាប់យុវជនដែលមានសិទ្ធិទទួលបាន Medicaid រហូតដល់ពួកគេមានអាយុ 21 ឆ្នាំ។*